វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia

# សេចក្តីថ្លែងការណ៍រួម
# អំពាវនាវឲ្យមានដំណោះស្រាយបន្ទាន់ចំពោះវិវាទដីធ្លីនៅកម្ពុជា

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤

---

យើងខ្ញុំ ជាសមាជិកនៃបណ្តាញសិទ្ធិដីធ្លីនិងលំនៅឋាន (LAHRIN)[1] ក្រោមការសម្របសម្រួលដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា សូមសម្តែងកង្វល់ដ៏ខ្លាំងរបស់យើងខ្ញុំអំពីផលប៉ះពាល់នៃវិវាទដីធ្លីដែលកំពុងកើតមាននៅកម្ពុជា។ វិវាទដីធ្លីនៅកម្ពុជាត្រូវបានគេមើលឃើញថាជាបញ្ហាដ៏ប្រឈមមួយនៃបញ្ហាប្រឈមធំៗបំផុតដែលប្រជាជនកម្ពុជាបានជួបប្រទះ។ ក្នុងករណីអាក្រក់បំផុត វិវាទដីធ្លីអាចនាំទៅដល់ការបាត់បង់ដីធ្លី និង លទ្ធភាពប្រើប្រាស់ធនធាន ដែលមិនមានសង្គតិភាពជាមួយការខិតខំសម្រេចគោលដៅកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា។ លើសពីនេះ វិវាទដីធ្លីក៏គឺជាបញ្ហាប្រឈមដ៏ធំមួយផងដែរចំពោះកេរ្តិ៍ឈ្មោះរបស់កម្ពុជានៅលើឆាកអន្តរជាតិ។ យោងទៅតាមរបាយការណ៍នៅក្នុងមូលដ្ឋានទិន្នន័យរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា បង្ហាញថាករណីវិវាទដីធ្លីខ្លះបាន និងកំពុងកើតឡើងអស់រយៈពេលច្រើនឆ្នាំមកហើយ ហើយចំណុចនេះបានប៉ះពាល់ជាខ្លាំងទៅដល់ស្ថានភាពរស់នៅ និងជីវភាពរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់។ កំណត់ត្រាទាំងនេះបង្ហាញថាមានកត្តាជាច្រើនដែលបណ្តាលឲ្យមានវិវាទដីធ្លី រួមមានគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅតំបន់ទីប្រជុំជន និងជនបទ សម្បទានដីសេដ្ឋកិច្ច និងសម្បទានផ្សេងៗទៀតដែលដំណើរការដោយក្រុមហ៊ុនជាតិ និងអន្តរជាតិ។ យោងតាម "ការវិភាគស្ថិតិរបស់វិវាទដីធ្លីនៅកម្ពុជា ឆ្នាំ ២០១៣" របស់សង្គមស៊ីវិល ករណីវិវាទដីធ្លីថ្មីសរុបចំនួន ២៨ ដែលបំពេញតាមលក្ខណៈវិនិច្ឆ័យរបស់មជ្ឈមណ្ឌលស្រាវជ្រាវ និងព័ត៌មាន[2] ត្រូវបានកត់ត្រាតាំងពីដើមឆ្នាំ ២០១៣។ ប៉ុន្តែ ចំនួននេះគឺទាបធៀបទៅនឹងករណីទាំងឡាយដែលបានកើតឡើងក្នុងឆ្នាំ ២០១០, ២០១១ និង ២០១២ ដែលមានករណីវិវាទថ្មីចំនួន ៣៩, ៣៩ និង ៤៦ ក្នុងឆ្នាំនីមួយៗតាមលំដាប់។

វិវាទដីធ្លីសរុបដែលត្រូវបានវិភាគដោយមជ្ឈមណ្ឌលស្រាវជ្រាវនិងព័ត៌មាន ដោយផ្អែកលើវិធីសាស្ត្ររបស់ខ្លួនក្នុងឆ្នាំ ២០១៣ គឺមានចំនួន ៤០៥។ ក្នុងចំណោមករណីទាំងនេះ ៨១ ករណីត្រូវបានដោះស្រាយក្នុងឆ្នាំ ២០១៣ ហើយ ១៣ ករណីវិវាទដីធ្លីត្រូវបានបោះបង់។ ជាលទ្ធផល ៧៧% ឬ ៣១១ ករណីក្នុងចំណោមវិវាទដីធ្លីសរុបចំនួន ៤០៥ ដែលត្រូវបានកត់ត្រា មិនត្រូវបានដោះស្រាយ

---

1: រួមមានសមាជិកបណ្តាញអង្គការមិនមែនរដ្ឋាភិបាល និង ដៃគូទាំងនៅថ្នាក់ជាតិ និង ថ្នាក់ខេត្តជាង ៥០ ។

2: វិវាទដីធ្លីដែលត្រូវបានផ្សាយក្នុងសារព័ត៌មាន ករណីវិវាទដីធ្លីដែលពាក់ព័ន្ធ ៥ គ្រួសារ ឬ ច្រើនជាង, ករណីវិវាទដីធ្លីដែលនៅមិនទាន់បានដោះស្រាយ ឬ ដែលត្រូវបានដោះស្រាយបានខ្លះ និង ករណីវិវាទដីធ្លីដែលត្រូវបានដោះស្រាយមុនឆ្នាំ ២០១៣ ត្រូវបានកាត់ចេញពីការវិភាគនេះ។ ប៉ុន្តែ ករណីទាំងឡាយដែលត្រូវបានដោះស្រាយក្នុងឆ្នាំ ២០១៣ ត្រូវបានដាក់បញ្ចូល។

យ៉ាងពេញលេញទេគិតត្រឹមឆ្នាំ ២០១៣។ ជាមួយចំនួននេះ គ្រួសាររងផលប៉ះពាល់ដែលត្រូវបានរាប់មានចំនួន ៦៥,៨៦៧ ហើយចំនួននេះអាចប៉ះពាល់ប្រជាពលរដ្ឋរហូតដល់ ៣០៩,៥៧៥ នាក់។ តួលេខនេះគឺស្មើនឹងប្រហែល ២.៣៥% នៃចំនួនគ្រួសារសរុបក្នុងទូទាំងប្រទេស។ ទន្ទឹមនឹងនេះ ក្នុងឆ្នាំ ២០១២ វិវាទដីធ្លីត្រូវបានដោះស្រាយបានច្រើនជាងក្នុងឆ្នាំផ្សេងៗទៀត។

គិតមកដល់ឆ្នាំ ២០១៣ សម្បទានដីសេដ្ឋកិច្ចចំនួន ៨០ សិប បាននាំឲ្យមានវិវាទ ហើយវិវាទទាំងនេះបានប៉ះពាល់គ្រួសារចំនួន ១៩,៧៥០ ឬ សមាជិកគ្រួសារចំនួន ៩២,៧៧៨ នាក់។

ករណីមួយនៃករណីទាំងឡាយដែលត្រូវបានដាក់បញ្ចូលក្នុងការវិភាគ គឺវិវាទរវាងក្រុមហ៊ុនអឹម ឌីអេស អ៊ីមផត អិចផត ខូអិលធីឌី (MDS Import Export Co, Ltd)[3] និង ៨៤ គ្រួសារដែលបានរស់នៅលើដីនោះតាំងពីឆ្នាំ ១៩៩៨។ ក្នុងវិវាទនេះ ដីអ្នកភូមិត្រូវបានឈូសឆាយដោយក្រុមហ៊ុន ហើយក្រោយមកអ្នកភូមិត្រូវបានរារាំងមិនឲ្យចូលក្នុងដីរបស់ខ្លួន។ លើសពីនេះតុលាការបានកោះហៅអ្នកភូមិ ចំនួនបីនាក់ពីបទឆ្លងកាត់តំបន់ហាមឃាត់នេះ។ មុនពេលអនុវត្តគម្រោង ពុំមានធ្វើការពិគ្រោះយោបល់ ឬ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) ត្រូវបានអនុវត្តនោះទេ[4]។ សហគមន៍បានធ្វើការអំពាវនាវយ៉ាងទទូចទៅដល់រាជរដ្ឋាភិបាល និងក្រុមហ៊ុនសូមដោះស្រាយវិវាទ ផ្តល់ការអភិវឌ្ឍនៅនឹងកន្លែង និងសំណងគ្រប់គ្រាន់ ក៏ដូចជា ការផ្តល់ប័ណ្ណកម្មសិទ្ធិដីនៅពេលបន្ទាប់។ ម្យ៉ាងទៀត អ្នកភូមិអំពាវនាវសូមឲ្យបញ្ឈប់ជាបន្ទាន់នូវរាល់រូបភាពនៃការគម្រាមកំហែង និងសុំឲ្យតុលាការដកការចោទប្រកាន់ប្រឆាំងនឹងអ្នកភូមិ។

វិវាទមួយទៀតដែលបានប៉ះពាល់ទៅដល់ប្រជាជនជាង ១,៩៦៣ គ្រួសារ ជាមួយក្រុមហ៊ុនយូញីនឌីវែលឡុបមេនត៍គ្រុប (Union Development Group)[5] នៅខេត្តកោះកុង ដែលកើតមានឡើងតាំងពីឆ្នាំ ២០០៨។ គម្រោងនេះត្រូវបានអនុវត្តដោយមិនមានធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមឲ្យបានសមស្របឡើយមុនពេលដំណើរការ។ ការពិគ្រោះយោបល់សាធារណៈអំពីគម្រោង និងផែនការដោះស្រាយផលប៉ះពាល់ មិនត្រូវបានអនុវត្តនៅក្នុងដំនើការគម្រោងនេះឡើយ។ នៅក្នុងនោះសំណងដែលបានផ្តល់ឲ្យត្រូវបានរកឃើញថាមិនគ្រប់គ្រាន់។ ប្រជាពលរដ្ឋត្រូវបានបណ្តេញចេញដោយបង្ខំទៅកន្លែងតាំងលំនៅឋានថ្មី ដែលមានហេដ្ឋារចនាសម្ព័ន្ធ និង សេវាសាធារណៈមិនល្អ។ អំពើ

---

[3]: រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់ដីទំហំ ២២៦៥ ហិកតានៅឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់ ឲ្យក្រុមហ៊ុនអឹមឌីអេស អ៊ីមផតអិចស្ពតខូអិលធីឌី (MDS Import Export Co, Ltd) ក្នុងឆ្នាំ ២០១០ សម្រាប់តំបន់សេដ្ឋកិច្ចពិសេស។

4: ក្រុមហ៊ុន និង អាជ្ញាធរមូលដ្ឋានមិនអនុញ្ញាតឲ្យអ្នកភូមិឆ្ការព្រៃរបោះដែលជាកន្លែងពួកគេធ្លាប់ដាំដំណាំ ក្រុមអឹមឌីអេស (MDS) នៅតែកំពុងឈូសឆាយចំការរបស់អ្នកភូមិ មន្ត្រីបរិស្ថានបានឃាត់ខ្លួនអ្នកភូមិពីបទឆ្លងកាត់ខុសច្បាប់លើដីរបស់ក្រុមហ៊ុនអឹមឌីអេស (MDS) អាជ្ញាធរមូលដ្ឋានបានព្រមានអ្នកភូមិមិនឲ្យដាំដំណាំលើដីព្រៃ។ តុលាការបានកោះហៅអ្នកភូមិបីនាក់ (លោក ទឹម ធឿន លោកស្រី គួយ ស្រីមៅ នៅថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០១៣ និង លោក បេ ប៊ិន នៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤) ពីបទឆ្លងកាត់ខុសច្បាប់លើដីព្រៃ។ បីករណីនៃការបាត់លំនៅឋាន (លោក បេ ឡេង និង អ៊ូ ផេង) នៅថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១៤។ សរុប មានករណីបាញ់ចំការចំនួនដប់ពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៤។

[5]: រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ដីសម្បទានទំហំ ៣៦,០០០ ហិកតានៅស្រុកបុទុមសាគរ និង គិរីសាគរ ខេត្តកោះកុង សម្រាប់រយៈពេល ៩៩ ឆ្នាំ។

ហិង្សាត្រូវបានប្រើដោយឆ្នាំសន្តិសុខទៅលើអ្នកភូមិដែលមិនព្រមចេញពីដី និងលំនៅឋានរបស់ពួកគេ។ ថ្មីៗនេះ គ្រប់ភាគីពាក់ព័ន្ធសំខាន់ៗទាំងអស់បានពិភាក្សាគ្នាដើម្បីស្វែងរកដំណោះស្រាយមួយចំពោះវិវាទនេះ[6]។ អ្នកភូមិទាំងឡាយដែលមិនព្រមទទួលសំណង បានអំពាវនាវដល់រាជរដ្ឋាភិបាលសូមផ្ទៀលដីលំនៅឋាន និងដីចំការរបស់ពួកគេចេញពីដីដែលកាន់កាប់ដោយក្រុមហ៊ុន។ ពួកគេក៏អំពាវនាវផងដែរសូមឲ្យកសាងហេដ្ឋារចនាសម្ព័ន្ធ និងពង្រឹងសេវាសាធារណៈមានស្រាប់នៅទីតាំងលំនៅឋានថ្មី។

ក្នុងឋានៈជាបណ្ដាញសិទ្ធិដីធ្លីនិងលំនៅឋាន យើងគាំទ្ររាជរដ្ឋាភិបាលដែលបានយកចិត្តទុកដាក់ក្នុងការទាក់ទាញការវិនិយោគ ដើម្បីអភិវឌ្ឍប្រទេស។ ប៉ុន្តែ ទន្ទឹមនឹងនេះ យើងខ្ញុំសូមសម្ដែងការសោកស្ដាយជាខ្លាំង និងការបដិសេធរបស់យើងចំពោះការវិនិយោគរបស់ផ្នែកឯកជនណាដែលមិនមានផែនការល្អត្រឹមត្រូវ និងដែលមិនត្រូវបានតាមដានមើលឲ្យបានគ្រប់គ្រាន់ ដូចជាសម្បទានដីសេដ្ឋកិច្ចមិនស្របច្បាប់ ដែលគឺជាមូលហេតុឫសគល់មួយនៃការរំលោភសិទ្ធិមនុស្ស ដែលប៉ះពាល់ប្រជាពលរដ្ឋជាច្រើន និងមិនបានរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ។

អាស្រ័យហេតុនេះ បណ្ដាញសិទ្ធិដីធ្លីនិងលំនៅឋានសូមផ្ដល់អនុសាសន៍ខាងក្រោមជូនដល់រាជរដ្ឋាភិបាលដើម្បីពិចារណា:

- ពន្លឿនការដោះស្រាយវិវាទដីធ្លី ដោយផ្ដល់ជូនស្ថាប័នពាក់ព័ន្ធនូវធនធានចាំបាច់។
- បង្កើនតម្លាភាពក្នុងចំណាត់ការតុលាការទាក់ទិននឹងវិវាទដីធ្លី។
- កំណត់អាទិភាពដើម្បីដោះស្រាយប្រកបដោយតម្លាភាពនូវករណីពហុភាគី ជាពិសេស ករណីទាំងឡាយដែលបានកើតមានជាយូរមកហើយ។
- តម្លាភាព ក្នុងការធ្វើផែនទី កំណត់ប្រភេទ និងចំណាត់ថ្នាក់ដីរដ្ឋ ដើម្បីកាត់បន្ថយវិវាទរវាងគម្រោងវិនិយោគ និងសហគមន៍មូលដ្ឋាន។
- បញ្ឈប់ការចាប់ខ្លួនសមាជិកសហគមន៍ដែលពាក់ព័ន្ធនឹងវិវាទដីធ្លី និងបញ្ឈប់ការប្រើប្រាស់កំលាំងយោធា ឬកំលាំងកងនគរបាលដើម្បីធ្វើការការពារទៅលើដីដែលបានកាន់កាប់ដោយសម្បទានិក។
- គ្រប់គម្រោងអភិវឌ្ឍន៍ត្រូវតែធ្វើការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមប្រកបដោយតម្លាភាព និងការចូលរួម ឲ្យស្របតាមបទដ្ឋានអន្តរជាតិ ដូចជាការពិគ្រោះយោបល់ជាសាធារណៈ មុនពេលគម្រោងអនុម័ត។
- ពន្លឿនការក្នុងការចុះបញ្ជី និងទទួស្គាល់សហគមន៍ជនជាតិដើមភាគតិច សហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារ សហគមន៍អេកូទេសចរណ៍ និងសហគមន៍នេសាទ។

---

6: សិក្ខាសាលាពិគ្រោះយោបល់ស្ដីពីការរិះរកដំណោះស្រាយចំពោះវិវាទដីធ្លីនៃករណី UDG ក្នុងខេត្តកោះកុង នៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ ដែលបានចូលរួមដោយតំណាងក្រសួងបរិស្ថាន អាជ្ញាធរថ្នាក់ក្រោមជាតិ សហគមន៍ និង អង្គការមិនមែនរដ្ឋាភិបាល។